com2doc/BOREIY HOTEL

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ...៧០.សសរ**

# សេចក្តីសម្រេច

## ស្តីពី

## ការកែសម្រួលគណៈកម្មការអន្តរក្រសួងដើម្បីបន្តដោះស្រាយគោលនយោបាយ ដីធ្លីជាមួយប្រជាពលរដ្ឋ នៅបុរីវប្បធម៌-ទេសចរណ៍អង្គរសៀមរាប គ្រប់គ្រងដោយអាជ្ញាធរអប្សរា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ ហៅថា " អាជ្ញាធរអប្សរា"

-បានឃើញអនុក្រឹត្យលេខ ៧៩/អនក្រ/បក ចុះថ្ងៃទី១៣ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី បុរីសណ្ឋាគារ

-បានឃើញអនុក្រឹត្យលេខ ៩៣/អនក្រ/បក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីអំពីការពង្រីកផ្ទៃដីបុរីសណ្ឋាគារអង្គរសៀមរាបគ្រប់គ្រងដោយអាជ្ញាធរអប្សរា

-យោងតាមសំណើរបស់ទីស្តីការគណៈរដ្ឋមន្ត្រី និង អាជ្ញាធរអប្សរា ។

## ស ម្រេ ច

ប្រការ១. – ចាត់ទុកជានិរាករណ៍ នូវសេចក្តីសម្រេចលេខ ៧១/សសរ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៩ និង សេចក្តីសម្រេចលេខ ៧៥/សសរ ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ២០០១ ។

ប្រការ២. – បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីបន្តដោះស្រាយសម្របសម្រួលជាមួយប្រជាពលរដ្ឋ ដែលកាន់កាប់ដីធ្លីនៅបុរីវប្បធម៌-ទេសចរណ៍ អង្គរសៀមរាប គ្រប់គ្រងដោយអាជ្ញាធរអប្សរាដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តម **ប៊ុន ណារិទ្ធ** | អគ្គនាយកអាជ្ញាធរអប្សរា | ប្រធាន |
| ២_លោក **សុខ លក្ខិណា** | អភិបាលរងខេត្តសៀមរាប | អនុប្រធាន |
| ៣- ឯកឧត្តម **ខួយ គឹមខ្ន** | ទីប្រឹក្សាប្រធានអាជ្ញាធរអប្សរា | អនុប្រធានអចិន្ត្រៃយ៍ |
| ៤-ឯកឧត្តម **ស្វួន ម៉េងគា** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ៥-ឯកឧត្តម **ស៊ួន ចាន់ថន** | មេធាវីរាជរដ្ឋាភិបាល | សមាជិក |
| ៦-ឯកឧត្តម **ឌុច ទននីតូ** | អគ្គនាយក នៃអគ្គនាយកដ្ឋានរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | សមាជិក |

គណៈកម្មការអន្តរក្រសួងនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

ប្រការ៣. – គណៈកម្មការអន្តរក្រសួងមានភារកិច្ច៖

ជំរុញការងារដោះស្រាយ បញ្ហាការកាន់កាប់ដីក្នុងទីតាំងបរិវេណបុរីវប្បធម៌-ទេសចរណ៍ ដែលកំណត់ដោយអនុក្រឹត្យលេខ ៧៩/អនក្រ បក ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីបុរីសណ្ឋាគារ និង អនុក្រឹត្យលេខ ៥៣/អនក្រ/បក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីអំពីការពង្រីកផ្ទៃដីបុរីសណ្ឋាគារអង្គរសៀមរាបគ្រប់គ្រង ដោយអាជ្ញាធរអប្សរា ។

ប្រការ៤. – ក្នុងទិសដៅធានាការពារផលប្រយោជន៍សាធារណៈ គណៈកម្មការអន្តរក្រសួងមានសិទ្ធិចាត់វិធានការសមស្របទាំងឡាយ ដោយយោងតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលដើម្បីអនុវត្តអនុក្រឹត្យ និងលិខិតបទដ្ឋានផ្សេងទៀតដែលទាក់ទងការងារដោះស្រាយគោលនយោបាយដីធ្លីក្នុង បុរីវប្បធម៌ - ទេសចរណ៍ ។

ប្រការ៥. – គណៈកម្មការអន្តរក្រសួងនេះមានក្រុមការងារមួយ ដែលត្រូវបង្កើតឡើងដោយសេចក្តីសម្រេចរបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងស្ថិតក្រោមការដឹកនាំរបស់អនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មការអន្តរក្រសួង ដើម្បីអនុវត្តការងារផ្ទាល់នៅមូលដ្ឋាន ។ សមាសភាពរបស់ក្រុមការងារត្រូវបានបញ្ជូនមកពីក្រសួង អង្គភាព អាជ្ញាធរ នានាដែលពាក់ព័ន្ធតាមសំណើរបស់ប្រធានគណៈកម្មការអន្តរក្រសួង ។

ប្រការ៦. – បណ្តាក្រសួង ស្ថាប័ន អង្គភាព អាជ្ញាធរដែលពាក់ព័ន្ធ ត្រូវចូលរួមសហប្រតិបត្តិការឱ្យបានពេញលេញជាមួយគណៈកម្មការអន្តរក្រសួងនេះ សំដៅឱ្យការដោះស្រាយគោលនយោបាយជាមួយប្រជាពលរដ្ឋបានទទួលលទ្ធផលវិជ្ជមាន ឆាប់រហ័ស ។

ប្រការ៧. – ថវិកាគោលនយោបាយសម្រាប់ចាត់ចែងសម្របសម្រួលផ្តល់ជូនប្រជាពលរដ្ឋ ដែលត្រូវចេញពីបុរីវប្បធម៌-ទេសចរណ៍ និងបណ្តាសោហ៊ុយចំណាយក្នុងដំណើរការដោះស្រាយដីធ្លីជាបន្ទុករបស់ អាជ្ញាធរអប្សរា ។

ប្រការ៨. – បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ៩. – ទីស្តីការគណៈរដ្ឋមន្ត្រី អាជ្ញាធរអប្សរា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ក្រុមប្រឹក្សាអ្នកច្បាប់ សាលាខេត្តសៀមរាប គ្រប់ក្រសួង-ស្ថាប័ន អង្គភាពដែលពាក់ព័ន្ធ និង សាមីជន ដូចក្នុងប្រការ២ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ២ និងប្រការ៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ